August 10, 2019

# អ្នកនាំពាក្យបក្សកាន់អំណាចថា វត្តមានទូតថ្មីអាមេរិក នឹងធ្វើឲ្យទំនាក់ទំនងល្អប្រសើរ



*លោក ប៉ាទ្រីក ម័រហ្វី (Patrick Murphy) ជាឯកអគ្គរដ្ឋទូតសហរដ្ឋអាមេរិកប្រចាំកម្ពុជា។*

ដោយ សេក បណ្ឌិត
**2019-08-10**

*អ្នកនាំពាក្យបក្សកាន់អំណាចថា វត្តមាន លោក ប៉ាទ្រីក ម័រហ្វី* (Patrick Murphy) *ជាឯកអគ្គរដ្ឋទូតសហរដ្ឋអាមេរិកថ្មីប្រចាំកម្ពុជានឹងធ្វើឲ្យទំនាក់ទំនង រវាងកម្ពុជានិងអាមេរិកមានលក្ខណៈល្អប្រសើរ។ ប៉ុន្តែអ្នកវិភាគថា ទំនាក់ទំនងរវាងកម្ពុជា និងប្រទេសមហាអំណាចមួយនេះ គឺអាស្រ័យលើទង្វើរបស់របបក្រុងភ្នំពេញ មិនមែនជាការនិយាយតែមាត់នោះទេ។*

*អ្នកនាំពាក្យបក្សប្រជាជនកម្ពុជា លោក សុខ ឥសាន និយាយថា អនាគតឯកអគ្គរដ្ឋទូតថ្មីសហរដ្ឋអាមេរិកប្រចាំកម្ពុជា លោក ប៉ាទ្រីក ម័រហ្វី ជាបុគ្គលមានបទពិសោធន៍ និងចំណេះដឹងការងារការទូតច្រើនឆ្នាំ ដូច្នេះយល់ថា ឯកអគ្គរដ្ឋទូតថ្មីរូបនេះ នឹងបំពេញការងារតាមក្រមសីលធម៌ និងវិជ្ជាជីវៈជាអ្នកការទូត។ លោកយល់ថា វត្តមានឯកអគ្គរដ្ឋទូតថ្មី នឹងពង្រឹងពង្រីកនូវទំនាក់ទំនងទ្វេភាគីឲ្យមានលក្ខណៈល្អប្រសើរ និងក៏គ្មានភាពល្អក់កករនឹងគ្នានោះឡើយ៖ «ផ្អែកទៅលើមូលដ្ឋាននេះ ហើយខ្ញុំយល់ថា ចំណងការទូតរវាងកម្ពុជា និងសហរដ្ឋអាមេរិកពិតជាត្រូវបានពង្រឹងពង្រីកទ្វេភាគី គឺថា មានលក្ខណៈល្អប្រសើរពាក្យល្អនោះ គឺល្អគ្រប់ផ្នែកទាំងអស់»។*

*ព្រឹទ្ធសភាអាមេរិកបានអនុម័តតែងតាំងលោក  ប៉ាទ្រីក ម័រហ្វី ជាឯកអគ្គរដ្ឋទូតថ្មីរបស់អាមេរិក គឺធ្វើឡើងក្នុងពេលដែលទំនាក់ទំនងរវាងសហរដ្ឋអាមេរិក និងកម្ពុជាកំពុងស្ថិតនៅក្នុងភាពល្អក់កករ និងរកាំរកូសខ្លាំង ក្រោយរបបក្រុងភ្នំពេញបានរម្លាយប្រជាធិបតេយ្យ និងសិទ្ធិមនុស្ស ហើយងាកទៅឱបក្រសោបមហាយក្សចិនកាន់តែខ្លាំង។*

*ប៉ុន្តែលោក សុខ ឥសាន យល់ថា ការខ្វែងគំនិតគ្នានាពេលកន្លងមកស្ថានទូតអាមេរិកនៅកម្ពុជា និងរដ្ឋាភិបាលកម្ពុជាមិនបានធ្វើឲ្យប៉ះពាល់ដល់ចំណងការទូតនៃប្រទេសទាំងពីរទេ ដែលនេះជារឿងធម្មតាក្នុងនាមជាប្រទេសប្រជាធិបតេយ្យ។*

អ្នកវិភាគនយោបាយដើងចាស់ បណ្ឌិត ឡៅ ម៉ុងហៃ យល់ថា បើរដ្ឋាភិបាលសព្វថ្ងៃចង់មានទំនាក់ទំនងល្អប្រសើរជាមួយសហរដ្ឋអាមេរិក គឺជាស្ថិតនៅលើការសម្រេចចិត្តរបស់រដ្ឋាភិបាលខ្លួនឯងថា ដែលសម្រេចចិត្តថា គួរឈោងចាប់ដៃជាមួយអាមេរិកត្រឹមកម្រិតណា?។ បណ្ឌិត ឡៅ ម៉ុងហៃ សង្កេតឃើញថា អ្វីដែលសហរដ្ឋអាមេរិកចង់បានពីរដ្ឋាភិបាលនាពេលកន្លងមក មានពីរចំណុចសំខាន់ៗ គឺទាមទារឲ្យកម្ពុជារក្សាគោលនយោបាយអព្យាក្រឹតអចិន្ត្រៃយ៍ និងត្រូវដោះលែងប្រធានគណបក្សសង្គ្រោះជាតិ លោក កឹម សុខា ដែលកំពុងជាប់ឃុំ៖ «បញ្ជាក់អាមេរិកឲ្យបានច្បាស់លាស់ថា កម្ពុជា គឺកាន់នយោបាយអព្យាក្រឹតភាព ហើយសូមឲ្យអាមេរិកជួយពង្រឹងជំហរអព្យាក្រឹតរបស់កម្ពុជាផង ហើយទី២ ដោះលែងលោក កឹម សុខា ទៅតាមការទាមទាររបស់សហរដ្ឋអាមេរិក»។

បណ្ឌិត ឡៅ ម៉ុងហៃ រំលឹកថា ការទាមទាររបស់សហរដ្ឋអាមេរិកកន្លងមកមិនមែនជាការជ្រៀតជ្រែកកិច្ចការផ្ទៃក្នុងរបស់កម្ពុជា ដូចការចោទប្រកាន់នោះទេ លោកបណ្ឌិតបញ្ជាក់ថា ផ្អែកលើកកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីសសហរដ្ឋអាមេរិកជាប្រទេសហត្ថលេខីធំមួយ ដែលមានតួនាទីតាមដាន និងជំរុញទៅរដ្ឋាភិបាលឲ្យគោរពសិទ្ធិមនុស្ស ប្រជាធិបតេយ្យ ដែលមានចែងក្នុងកិច្ចព្រមព្រៀងនេះ។

ចំពោះឥទ្ធិពលលោក ប៉ាទ្រីក ម័រហ្វី (Patrick Murphy) ជាឯកអគ្គរដ្ឋទូតសហរដ្ឋអាមេរិកប្រចាំកម្ពុជា បណ្ឌិត ឡៅ ម៉ុងហៃ យល់ថា បើផ្អែកលើបទពិសោធន៍ការងារ និងចរិតលក្ខណៈរបស់ លោក ប៉ាទ្រីក ម័រហ្វី ឯកអគ្គរដ្ឋទូតថ្មីរូបនេះ អាចនឹងបង្កើតបរិយាកាសថ្មីមួយធ្វើឲ្យចំណងការទូតកម្ពុជាអាមេរិកវិលមកភាពប្រក្រតីឡើងវិញ៖ «ចរិតលក្ខណៈ គឺមិនដូចមុនៗ ប្រហែលជាមានគំនិត និងការប៉ិនប្រសប់ខុសប្លែកពីឯកអគ្គរដ្ឋទូតមុនៗ ហើយមានរបៀបរបបគាត់ទំនាក់ទំនងគាត់ជាមួយអ្នកដទៃហ្នឹងក្រែងលោគាត់មានអីថ្មី»។

ព្រឹទ្ធសភាអាមេរិកបានអនុម័តជាផ្លូវការកាលពីថ្ងៃទី១ ខែសីហាកន្លងទៅ ដោយយល់ព្រមតែងតាំងលោក ប៉ាទ្រីក ម័រហ្វី ជាឯកអគ្គរដ្ឋទូតវិសាមញ្ញ និងពេញសមត្ថភាពរបស់សហរដ្ឋអាមេរិក ប្រចាំកម្ពុជា។ ការអនុម័តនេះ ក្រោយពី តំណែង ឯកអគ្គរដ្ឋទូតសហរដ្ឋអាមេរិកនៅទំនេរជាងកន្លះឆ្នាំ ក្រោយ ឯកអគ្គរដ្ឋទូតចាស់ លោក វីល្លៀម ហៃដ៍ (William Heidt) បានចប់អាណត្តិ កាលពីចុងឆ្នាំ២០១៨ កន្លងទៅ។

លោក ប៉ាទ្រីក ម័រហ្វី បានប្តេជ្ញាជំរុញស្តារលទ្ធិប្រជាធិបតេយ្យ និងសិទ្ធិមនុស្សនៅកម្ពុជាឡើងវិញ។ ការបញ្ជាក់ពីគោលជំហរ និងការប្តេជ្ញាចិត្តនេះ ធ្វើឡើងក្នុងសវនាការសួរដេញដោលផ្ទាល់មាត់មួយ កាលពីថ្ងៃទី៤ ខែធ្នូ ដោយគណៈកម្មាធិការកិច្ចការបរទេស នៃព្រឹទ្ធសភាអាមេរិក មុននឹងសម្រេចតែងតាំងលោក ជាឯកអគ្គរដ្ឋទូតពេញសមត្ថភាព និងវិសាមញ្ញថ្មីរបស់សហរដ្ឋអាមេរិកប្រចាំកម្ពុជា ជំនួសលោក វីល្លៀម ហៃដ៍ (William A . Heidt) ដែលទើបផុតអាណត្តិ។

ឯកអគ្គរដ្ឋទូតអាមេរិកថ្មីរូបនេះគាំទ្រជំហរដាក់ទណ្ឌកម្មបន្ថែមលើក្រុមមេដឹកនាំរបបក្រុងភ្នំពេញ ដើម្បីដាក់សម្ពាធមកលើរបបក្រុងភ្នំពេញ ដើម្បីឲ្យរបបនេះ ងាកមកស្តារប្រជាធិបតេយ្យ និងគោរពសិទ្ធិមនុស្សនៅកម្ពុជាឡើងវិញ៕